# ដីកាសម្រេចរក្សាការពារ

## ផ្នែកទី១ ស្ដីពី សញ្ញាណទូទៅនៃដីការក្សាការពារ

ធ្វើបទបង្ហាញដោយ ៖

លោកស្រីមេធាវី មាស ស៊ីថន

# នីតិវិធីនៃការចាត់ចែងរក្សាការពារ

- អ្វីទៅជានីតិវិធីរក្សាការពារ? ដើម្បីបង្កើតអោយមានការការពារតើត្រូវមានលក្ខខណ្ឌអ្វីខ្លះ?

  នីតិវិធីរក្សាការពារមានពីតំណាក់កាល ៖

  ១. នីតិវិធីនៃការសម្រេចសេចក្តី

  ២. នីតិវិធីអនុវត្តដោយបង្ខំ

## ២. សញ្ញាណទូទៅ

**លក្ខណៈពិសេស**

នីតិវិធីរក្សាការពារមានលក្ខណៈបណ្ដោះអាសន្ន និងបន្ទាប់បន្សំ

មានន័យថា ដំណើរការនៃនីតិវិធីរក្សាការពារ មិនអាចសម្រេចអំពីសិទ្ធិរបស់ភាគីជាស្ថាពរបានទេ វាគ្រាន់តែជាវិធានបណ្ដោះសន្ទុះប៉ុណ្ណោះ ដើម្បីសម្រេចនៅសិទ្ធិបាន ភាគីត្រូវដាក់បណ្ដឹងអង្គសេចក្ដី។

## <u>មានភាពបន្ទាន់</u>

រក្សាការពារនឹងមិនមានន័យបើ កូនបំណុលចាត់ចែងទ្រព្យសម្បត្តិរបស់គេអស់ ឬស្ថានភាពណាមួយរបស់ម្ចាស់បំណុលមិនត្រូវបានការពារ ។

## <u>វិធីអនុវត្តដោយស្វាត់ៗ</u>

មានករណីខ្លះបើអោយកូនបំណុលបានដឹងមុននោះការអនុវត្តរក្សាការពារនិងមិនអាចធ្វើបានដោយកូនបំណុលនិងធ្វើការលាក់បាំង ឬចាត់ចែងទ្រព្យរបស់ពួកគេ ។

# ការពន្យល់គ្រួសៗអំពីនីតិវិធីរក្សាការពារ

## សមត្ថកិច្ចតុលាការ

- តុលាការនៃបណ្តឹងអង្គសេចក្តី
- តុលាការនៃវត្ថុដែលត្រូវរឹបអូស ឬវត្ថុដែលជាកម្មវត្ថុវិវាទតាំងនៅ ។

ដាក់ពាក្យសុំ

តុលាការធ្វើការវិនិច្ឆ័យ តើទទួលស្គាល់ការរឹមអូស ជាបណ្ដោះអាសន្នដែរ ឬទេ?

មិនទទួលស្គាល់ លើកចោលពាក្យសុំ

ទទួលស្គាល់ នូវការរឹបអូស ត្រូវចេញដីការ សម្រេចរក្សាការពារ

នីតិវិធីនៃការអនុវត្ត ឧ. ស្ដីពីដីដែលត្រូវបានទទួលស្គាល់នូវការរឹបអូសជាបណ្ដោះអាសន្ន ត្រូវចុះអំពីការរឹបអូស ជាបណ្ដោះអាសន្ន នៅក្នុងសៀវគោលបញ្ជីដីធ្លី ។

**នីតិវិធីរក្សាការពារ**

ត្រូវធ្វើយ៉ាងណាកុំអោយកូនបំណុលលាក់ ឬ ប្រើប្រាស់ទ្រព្យ សម្បត្តិអស់

**នីតិវិធីបណ្តឹង**

ត្រូវខំប្រឹងទាមទារ និងបញ្ជាក់ភស្តុតាង ដើម្បីអោយតុលាការទទួលស្គាល់សិទ្ធិ នឹងបានឈ្នះក្តី

**នីតិវិធីអនុវត្ត**

រឹបអូស-ប្តូរជាប្រាក់-សងបំណុល

- ដីការក្សាការពាររដ្ឋប្បវេណី
  - ការរឹបអូសជាបណ្ដោះអាសន្ន
    - អចលនវត្ថុ
    - ចលនវត្ថុ
    - សិទ្ធិលើបំណុល
  - ការចាត់ចែងជាបណ្ដោះអាសន្ន
    - ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទ
      - ការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់
      - ការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែង
    - ការចាត់ចែងជាបណ្ដោះអាសន្ន ដែលកំណត់ឋានៈជាបណ្ដោះអាសន្ន

# -ពាក្យសុំ

ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ និងសេចក្តីបញ្ជាក់ដំបូង មានចែងក្នុងមាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## <u>ចំណុចដែលត្រូវសរសេរក្នុងពាក្យសុំ</u>

១. ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋាន របស់ភាគី ហើយនឹង ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

(ចំនុចទី១ នេះត្រូវសរសេរ អោយបានជាក់លាក់ បើមិនអាចកំណត់បាន ត្រូវកែតម្រូវ បើមិនអាចកែត្រូវលើកចោលពាក្យសុំ)

២. ខ្លឹមសារនៃដីកាសម្រេចរក្សាការពារ ដែលអ្នកដាក់ពាក្យសុំទាមទារ

ក. ការរឹបអូសជាបណ្ដោះអាសន្ន (CCP មាត្រា ៥៣១-ក)

. ការរឹបអូសជាបណ្ដោះអាសន្ននូវអចលនវត្ថុ

. ការរឹបជាបណ្ដោះអាសន្ននូវចលនវត្ថុ

. ការរឹបអូសជាបណ្ដោះអាសន្ននូវសិទ្ធិលើបំណុល ជាដើម

ខ.ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទ (CCP មាត្រា ៥៣១-ខ)

. ការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់

. ការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែង

គ. ការចាត់ថ្នែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន

. ការចាត់ថ្នែងបណ្តោះអាសន្នអោយបង់ប្រាក់ជាបណ្តោះអាសន្ន

. ការចាត់ថ្នែងជាបណ្តោះអាសន្នដែលហាមឃាត់ការសាងសង់ ជាដើម

៣. សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ

អត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវការពារ

៤. ភាពចាំបាច់នៃការរក្សាការពារ

ភាពចាំត្រូវខុសគ្នាទៅតាមស្ថានភាព និងប្រភេទដីកាសម្រេចរក្សាការពារ ។

# ១. ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នជាដីកាសម្រេចដែលមានគោលបំណងអោយសងជាប្រាក់។

## ខ្លឹមសារ

## ចំពោះអចលនវត្ថុ

រឹបអូសជាបណ្តោះអាសន្ននូវអចលនវត្ថុរបស់កូនបំណុលដែលមានប័ណ្ណសំគាល់សិទ្ធិ០០០០០១ ស្ថិតនៅភូមិ១ ផ្លូវ២ សង្កាត់ទួលគោក ខណ្ឌឬស្សីកែវ ។

**ចំពោះចលនវត្ថុ**

វិបអូសជាបណ្តោះអាសន្ននូវចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុលរហូតដល់គ្រប់នឹងតម្លៃសិទ្ធិលើបំណុលដែលម្ចាស់បំណុលមានចំពោះកូនបំណុល ។

**ចំពោះសិទ្ធិលើបំណុល**

វិបអូសជាបណ្តោះអាសន្ននូវសិទ្ធិលើបំណុលដូចមានក្នុងឧបសម្ព័ន្ធដែលកូនបំណុលមានចំពោះកូនបំណុលទី៣ ដើម្បីរក្សាការពារការអនុវត្តសិទ្ធិលើបំណុលដែលម្ចាស់បំណុលមានចំពោះកូនបំណុល។

## ភាពចាំបាច់នៃការរឹបអូសជាបណ្តោះអាសន្ន

ករណីមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ (CCP មាត្រា ៥៩៥ កថាខណ្ឌទី១ )

**<u>ឧទាហរណ៍</u> ករណីប្រាក់កម្ចី**




**១.ខ្ចីប្រាក់ពី** B
**២.មិនព្រមសង**

ប្ដឹងទៅតុលាការ ដើម្បីទាមទារ ប្រាក់កម្ចីពី A

ដីL

យកដីទៅលក់អោយគេ ដើម្បីបានប្រាក់មក ចាត់ចែងការងារផ្សេងៗ រឿងសងប្រាក់B ទុកម្ដុំសិន

ចុងក្រោយពេលដែល B ឈ្នះក្ដី ហើយ តុលាការបង្គាប់អោយ A សងប្រាក់នោះមក B ប៉ុន្តែ B មិនទទួលបានអ្វីក្រៅពីសាលក្រម ដែលឈ្នះក្ដីប៉ុណ្ណោះ ព្រោះA បានចាត់ចែង ទ្រព្យសម្បត្តិរបស់គាត់អស់ទៅហើយ ។

ដើម្បីបង្ការកុំអោយ A ចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនអស់ ហើយ Bឈ្នះក្ដី តែមិនអាចអនុវត្តសិទ្ធិលើបំណុលរបស់ខ្លួនបាននោះ B ត្រូវដាក់រក្សាការពារដើម្បីរឹបអូសនូវទ្រព្យរបស់ A ជាបណ្ដោះអាសន្នទម្រាំការសម្រេចក្ដីជាស្ថាពរមកដល់ ហើយ B អាចធ្វើការអនុវត្តដោយបង្ខំបាន ។



. ខ្ញុំចង់ទាមទារអោយសងប្រាក់កម្ចី

.ដោយសារកូនបំណុលមានទ្រព្យសម្បត្តិតែមួយគត់ គឺដី(L) ហេតុនេះ ពេលខ្ញុំឈ្នះក្ដី ខ្ញុំចង់អោយគាត់លក់ដីនេះយកប្រាក់មកសងខ្ញុំ ។

.ចង់ធ្វើយ៉ាងណាកុំអោយគាត់លក់ទ្រព្យតាមទំនើងចិត្តរបស់គាត់

.ចង់ទុកដីនៅដូចសព្វថ្ងៃ

. ចង់រក្សាស្ថានភាព

.តើគួរធ្វើបែបណា?

សិទ្ធិដែលត្រូវរក្សាការពារ តើសិទ្ធិនោះជាសិទ្ធិអ្វី ?

ប្រសិនបើយើងមើលលើឧទាហរណ៍ខាងលើ គឺ ***គាត់ទាមទារប្រាក់កម្ចី ហើយក្តីបារម្ភរបស់គាត់ គឺខ្លាចក្ជូនបំណុល ចាត់ចែងទ្រព្យដែលខ្លួនមានអស់***

អ្វីដែល  B ចង់រក្សាការពារ គឺ ***សិទ្ធិទាមទារអោយសងប្រាក់កម្ចី*** (ជាសិទ្ធិលើបំណុល )

ហេតុនេះប្រភេទនៃការចាត់ចែងរក្សាការពារដែលត្រូវធ្វើ គឺ ***<u>ការរឹបអូសជាបណ្តោះអាសន្ន ។</u>***

**ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទ**

ដីកាប្រភេទនេះ គឺមិនមានគោលបំណងអោយសងជាប្រាក់ទេ

**ខ្លឹមសារ**

**ហាមឃាត់ការផ្ទេរការកាន់កាប់**

១. ចាត់ចែងជាបណ្តោះអាសន្នដោយហាមឃាត់កូនបំណុលមិនអោយមានការផ្ទេរការកាន់កាប់អោយអ្នកដទៃ ឬប្តូរឈ្មោះ អ្នកកាន់កាប់ចំពោះអចលនវត្ថុនានាដូចជា.........

២.ចាត់ចែងជាបណ្ដោះអាសន្នដោយអោយកូនបំណុលលះបង់ការកាន់កាប់វត្ថុខាងលើ ហើយប្រគល់អោយអាជ្ញាសាលា

ហាមឃាត់មិនអោយចាត់ចែង

ចាត់ចែងជាបណ្ដោះអាសន្នដោយហាមឃាត់មិនអោយកូនបំណុល ផ្ទេរ ដាក់បញ្ចាំ ហ៊ីប៉ូតែក ជួល និងចាត់ចែងគ្រប់ប្រភេទផ្សេងទៀត ចំពោះអចលវត្ថុនានាដូចមាន.................

## ភាពចាំបាច់នៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទ

បើមានការបារម្ភថា ម្ចាស់បំណុលនិងមិនអាចអនុវត្តសិទ្ធិ ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ ។(CCP មាត្រា ៥៣១ ចំណុច ខ មាត្រា ៥៤៨ កថាខណ្ឌទី១)




១. ជួលផ្ទះមួយខ្នងអោយទៅ B

២. B មិនបង់ថ្លៃឈ្នួល

៣. រំលាយកិច្ចសន្យា

៤. គេមិនប្រគល់ផ្ទះមកវិញ




ជួលផ្ទះអោយទៅC ហើយប្រគល់ការកាន់កាប់ទៅ C រួចក៏ចាកចេញ

មានតែដាក់បណ្ដឹងទៅតុលាការទេ ទើបអាចទាមទារអោយ Bប្រគល់ផ្ទះមកវិញ



Aចង់ដាក់បណ្តឹងទៅតុលាការដើម្បីទាមទារអោយB ប្រគល់ផ្ទះអោយខ្លួនវិញ ប៉ុន្តែមិនទាន់បានដាក់ផង B បានប្រគល់ការកាន់កាប់ផ្ទះទៅCហើយចាកចេញបាត់ ។ ចុងបញ្ចប់ B ឈ្នះក្តី តែមិនអាចអនុវត្តបាន



១.ខ្ញុំចង់អោយគេរើផ្ទះហើយប្រគល់ផ្ទះមកអោយខ្ញុំវិញ

២. បើសិនជាតតិយជនមកកាន់កាប់ផ្ទះរបស់ខ្ញុំ តាមទំនើងចិត្ត ដើម្បីដេញតតិយជននោះចេញ ត្រូវដាក់បណ្តឹងថ្មីទៀត ហេតុនេះវាលំបាកណាស់ដែលខ្ញុំត្រូវធ្វើបណ្តឹងថ្មីរហូត

៣. ខ្ញុំចង់ធ្វើយ៉ាងណាកុំអោយមានការប្តូរអ្នកកាន់កាប់

៤. ចង់ទុកអោយ B នៅតែកាន់កាប់ដដែល

៥. ចង់រក្សាស្ថានភាពបច្ចុប្បន្ន

សិទ្ធិដែលត្រូវរក្សាការពារ គឺសិទ្ធិលើបំណុលជាប្រាក់ ឬយ៉ាងណាដែរ?

ចង់រក្សាការពារសិទ្ធិទាមទារអោយរើ និងប្រគល់ផ្ទះមកវិញ ហេតុនេះ សិទ្ធិដែលត្រូវរក្សាការពារមិនមែនជាសិទ្ធិលើបំណុលទេ ។

បើវាមិនមែនជាសិទ្ធិលើបំណុល ប្រភេទនៃការចាត់ចែងរក្សាការពារដែលត្រូវធ្វើ គឺ *ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទ*

ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ដែលកំណត់ឋានៈជាបណ្តោះអាសន្ន

ដីកាប្រភេទនេះ គឺមិនមានគោលបំណងអោយសងជាប្រាក់ទេ

ខ្លឹមសារ

១. ការចាត់ចែងជាបណ្តោះអាសន្នអំពីឋានៈជាបុគ្គលិក

២. ការចាត់ចែងជាបណ្តោះអាសន្នដោយបង្គាប់អោយកូនបំណុលបង់ប្រាក់ខែដល់ម្ចាស់បំណុលរៀងរាល់ខែ ត្រឹមថ្ងៃទី១០ ចំនួន ៣០០$ ចាប់ពីខែធ្នូ ឆ្នាំ២០១៦ រហូតដល់ពេលសាលក្រមចូលជាស្ថាពរ ។

៣. ការចាត់ចែងជាបណ្តោះអាសន្នដោយអោយ A កាន់កាប់លើដី L ជាបណ្តោះអាសន្នចាប់ពី........ រហូតដល់សាលក្រមចូលជាស្ថាពរ

**ភាពចាំបាច់ចំពោះការចាត់ចែងជាបណ្តោះអាសន្ន ដែលកំណត់ឋានៈជាបណ្តោះអាសន្ន**

បើមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល





1.គ្រោះថ្នាក់ចរាចរណ៍
2.ចូលពេទ្យ ហើយឈប់សម្រាកការងារ
3.គ្រួសារគាត់ខ្វះប្រាក់សម្រាប់ចិញ្ចឹមជីវិត និងមើលជម្ងឺ



ចង់បានប្រាក់សំណងការខូចខាត

ប្ដឹងទៅតុលាការទាមទារសំណងការខូចខាត

ប៉ុន្តែក្នុងអំឡុងពេលទាមទារមិនដឹងបានប្រាក់ពីណាដើម្បី

ផ្គត់ផ្គង់ជីវភាពម្យ៉ាងត្រូវមើលថៃអ្នកជម្ងឺ



. Aចង់បានប្រាក់សម្រាប់ចិញ្ចឹមជីវិតភ្លាមៗ

. គាត់ចង់ដាក់បណ្តឹងទាមទារសំណងនៃការខូចខាតពីB តែនៅពេលដែលគាត់រងចាំលទ្ធផល គាត់មិនអាចចិញ្ចឹមជីវិតរបស់គាត់បាន

. គាត់ចង់ទាមទារអោយគេបង់ប្រាក់នៃសំណងការខូចខាតដែលនឹងទទួលបាននាពេលអនាគតមួយភាគជាមុនសិន

. ពោលគឺគាត់ចង់ឲ្យមានការផ្លាស់ប្តូរស្ថានភាពបច្ចុប្បន្ន

ករណីនេះ ប្រភេទនៃការចាត់ចែងរក្សាការពារដែលត្រូវធ្វើគឺ *ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន*

## ឯកសារយោង

១.ក្រមនីតិវិធីរដ្ឋប្បវេណី

២. សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី (ភាគ ២ ៖ ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ

៣. ឯកសារមេរៀន របស់លោកសាស្រ្តាចារ្យ Uchiyama jun ស្តីពី ទ្រឹស្តីទូទៅនៃការរក្សាការពាររដ្ឋប្បវេណី

# សូមអរគុណ